ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ៦២៧ /២៣ គ.ជ.ក

# របាយការណ៍ខែកញ្ញា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែតុលា ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្ដាប្រទេសមួយចំនួន គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណាល់គេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍

ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយ អង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ២. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការអប់រំដោយផ្ទាល់

##### ១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែកញ្ញា ឆ្នាំ២០២៣នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន ១៦.៥៥៤លើក មានអ្នកចូលរួមសរុបចំនួន ៦៤០.៧៤៧នាក់ (ធៀបនឹងខែសីហាមានចំនួន ៤៨៩.០០៧នាក់ គឺមានកើនឡើងចំនួន ១៥១.៧៤០នាក់ ស្មើនឹង ៣១,០៣% ក្នុងនោះស្ត្រីចំនួន ៣៧០.៥០៨នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៨ | ៦៩៣៣ | ២៤៧២ | ៥៧៣ | ២០៧៧០ | ៩៨២៧ |
| សរុប ក្រសួង ស្ថាប័ន | | ៤៨លើក | ៦.៩៣៣នាក់ | ២.៤៧២នាក់ | ៥៧៣លើក | ២០.៧៧០នាក់ | ៩.៨២៧នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ១.០០២ | ៦៣.៦០១ | ៣១.៧៧៣ | ១.៤០៤ | ៦៦.៩៥៨ | ៣៦.៦៣២ |
| ៣ | ខេត្តបាត់ដំបង | ៨២៩ | ៤៣.៥៣០ | ២២.៥៣៩ | ៦០៥ | ២១.៧២៦ | ១១៦.៦៩៣ |
| ៤ | ខេត្តពោធិ៍សាត់ | ៤១៦ | ២០.៤១៨ | ១១.៣៨៥ | ១៥២ | ៧.១៣០ | ៣.៦១០ |
| ៥ | ខេត្តសៀមរាប | ៣៤៩ | ៥៣.៤៩០ | ៣០.៧៩៧ | ៩៨ | ២.៨៦១ | ១.៦៤៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧៦៨ | ៣៩.៤២៥ | ១០.១២០ | ៣៨៦ | ១០.៩៥០ | ៥.៣៤២ |
| ៧ | ខេត្តកំពង់ចាម | ១.៨៦៧ | ១១៩.៧៦៥ | ៦.៨៧៣ | | | |
| ៨ | ខេត្តព្រះសីហនុ | ៦៩ | ៣.៣០៤ | ១.៥១២ | | | |
| ៩ | ខេត្តព្រះវិហារ | ៤ | ៣២៦ | ១៩៣ | | | |
| ១០ | ខេត្តស្វាយរៀង | ៤០០ | ១៨.១៤០ | ១០.៣០៨ | | | |
| ១១ | ខេត្តប៉ៃលិន | ១០២ | ២.១៩២ | ៥០៣ | ៤១ | ១.៦៤៣ | ៤៦៥ |
| ១២ | ខេត្តកោះកុង | | | ១២៣ | ២.៦៥៦ | ១.៣១៧ | |
| ១៣ | ខេត្តកំពត | ១ | ២៨៧ | ១៨៥ | | | |
| ១៤ | ខេត្តកំពង់ធំ | ២៨៩ | ១៦.២១០ | ៨.៩៤៥ | ៥០ | ៣.៨៦១ | ២.១២៣ |
| ១៥ | ខេត្តតាកែវ | ៣០៧ | ១១.១៣២ | ៥.៩៦៩ | ១០៦ | ៣.៦២៧ | ២.១៥៨ |
| ១៦ | ខេត្តក្រចេះ | ៣៤ | ២.២៩៣ | ១២៧៦ | | | |
| ១៧ | ខេត្តកែប | ២៩ | ៣.៤៨៥ | ១.៧៥៣ | ៦៦ | ២.៥៦០ | ១.៤៦០ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តតេនគិរី | | | | ៤១០ | ១៦.៤៣៩ | ៧.៨៥៤ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២១ | ខេត្តព្រៃវែង | ២៩៦ | ២៣.៩៩៤ | ១០.១៨៣ | ២៣ | ៩៦៧ | ៥២២ |
| ២២ | ខេត្តត្បូងឃ្មុំ | ២២៣២ | ៣២០៤៥ | ១៤.៥៥៨ | ៨០ | ២.២៩១ | ១.០៥២ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៧២៤ | ១២.២២១ | ៦.៩៨២ | ១៣៧ | ៣.៩៩០ | ២.២៩២ |
| ២៤ | ខេត្តឧត្តរមានជ័យ | ១ | ៨៦៦ | ៣៨២ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៩.៧១៩លើក | ៤៦៦.៧២៤នាក់ | ១៧៦.៣៥៩នាក់ | ៦.២១៤លើក | ១៤៦.៣២០នាក់ | ១៩១.៨៥០នាក់ |
| សរុបរួម | | ១៦.៥៥៤លើក | | ៦៤០.៧៤៧នាក់ | | ៣៧០.៥០៨នាក់ | |

១.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- ខេត្តបន្ទាយមានជ័យ៖
  - អង្គការកល្យាណមិត្ត បានផ្សព្វផ្សាយបំណិនជីវិត ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន ៣៧៥នាក់។
  - អង្គការតំណក់ទឹក បានចុះធ្វើសកម្មភាពបណ្ណាល័យចល័ត អប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ២០៥នាក់ (ស្រី ១០៧នាក់)។
  - អង្គការសាម៉ារីតាន់ភឺស បានអប់រំសហគមន៍អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំនួន ៣១៩នាក់ (ស្រី ១៤៤នាក់) កុមារ ២៧នាក់ (កុមារី ១៣នាក់)។
  - អង្គការ IOM បានប្រឹក្សាយោបល់ដោយផ្ទាល់ជាលក្ខណៈឯកជន ជាមួយពលករវិលត្រលប់ មានដូចជា៖ ១-ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពចំនួន ៣៣នាក់ (ស្រី ០៨នាក់)។ ២-ឱកាសទទួលបានការងារក្នុងស្រុកចំនួន ៣២នាក់ (ស្រី ០២នាក់)។
- ខេត្តសៀមរាប៖ អង្គការមូលនិធិអេ២១ បានផ្សព្វផ្សាយអប់រំ ស្តីពីអំពើជួញដូរមនុស្ស និងសុវត្ថិភាពប្រព័ន្ធអនឡាញ នៅតាមសហគមន៍ ចំនួន ០៧លើក អ្នកចូលរួមចំនួន ១១៦នាក់ (ស្រី ៥០នាក់)។

**១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន ២.០៤៩នាក់។
- លេខាធិការដ្ឋាន គ.ខ.ប.ជ ផ្សព្វផ្សាតាមប៉ុស្តិ៍វិទ្យុ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសរុបចំនួន ៣៣៧លើក មានខេត្តៈ (ត្បូងឃ្មុំ ១៨០លើក សៀមរាប ១០៧លើក ព្រៃវែង ៥០លើក កំពង់ចាម ១១លើក)។

**១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- ខេត្តកំពង់ធំ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយការិយាល័យជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត ដើម្បីចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ស្តីពីការផ្សព្វផ្សាយច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅវិទ្យុជាតិខេត្តកំពង់ធំ FM 98.3 MHz។
- ខេត្តកំពង់ចាម៖
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនចំនួន ០១លើក លើប្រធានបទ "ការការពារ និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស"។
  - មន្ទីរកិច្ចការនារីខេត្ត បានចូលរួមជាវាគ្មិនចំនួន ០១លើក លើប្រធានបទ៖ ១.ការការពារ និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ២.ការលើកកម្ពស់ស្ត្រី និងក្មេងស្រីដើម្បីសមភាពយេនឌ័រ។

១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- ខេត្តសៀមរាបៈ វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ សហការជាមួយអង្គការទេសន្តរប្រវេសន៍ បានចែកខិតប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជ្រើសរើសបេក្ខជនចូលរៀនជំនាញវិជ្ជាជីវៈ ចំនួន ១.២៥៦ខិតប័ណ្ណ។
- ខេត្តបន្ទាយមានជ័យៈ អង្គការសាម៉ារីតាន់ភឺស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ ចំនួន ៤៥៧នាក់ (ស្រី ១៤០នាក់) កុមារ ១១៣នាក់ (កុមារី ៣២នាក់)។
- ខេត្តបាត់ដំបងៈ អង្គការសាម៉ារីតាន់ភឺស បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១.២៦២សន្លឹក និងខិត្តប័ណ្ណទប់ស្កាត់ការជួញដូរមនុស្ស ១១៤៧សន្លឹក។

# ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

## ២.១. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ២២៤.៨៨៥នាក់ (ស្រី ៩៩.៦២០នាក់) អនីតិជន ៣.៤៥០នាក់ (ស្រី ១.២២៨នាក់)៖
    - ស្របច្បាប់ ១៧០.៣៨៩នាក់(ស្រី ៧៧.៨៥៧នាក់)អនីតិជន ២៥១នាក់(ស្រី ៧១នាក់)
    - មិនស្របច្បាប់ ៥៤.៣២៨នាក់(ស្រី២១.៧១២នាក់) អនីតិជន៣.១៦៧នាក់(ស្រី១.១៤៤នាក់)
    - ដាច់ការទាក់ទង ១៦៨នាក់ (ស្រី ៥១នាក់) អនីតិជន ៣២នាក់ (ស្រី ១៣នាក់)។
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១២៤.៣៣៤នាក់ (ស្រី ៥៦.១៩៧នាក់) អនីតិជន ៤១១នាក់ (ស្រី ១៦០នាក់)។

## ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ ក្រចេះ មណ្ឌលគិរី និងខេត្តស្វាយរៀង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៣០៧គោលដៅមនុស្សចំនួន ១.៧៥២នាក់ (ស្រី ១.២៦២នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ក្រចេះ ព្រះវិហារ និងតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ២៥លើក។

## ២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ចំនួន ១៧៧នាក់(ស្រី ១២នាក់) មាន១៤សញ្ជាតិ រួមមានៈ ចិន ៩៦នាក់ កូរ៉េខាងត្បូង ៤១នាក់ (ស្រី ០៤នាក់) អាមេរិក ១៨នាក់ (ស្រី ០៤នាក់) បារាំង ០៧នាក់ (ស្រី ០១នាក់) កាណាដា ០៣នាក់ (ស្រី ០១នាក់) ម៉ាឡេស៊ី

០៣នាក់ អូស្ត្រាលី ០២នាក់ ជប៉ុន ០១នាក់ អាឡឺម៉ង់ ០១នាក់ ថៃ ០១នាក់(ស្រី) វៀតណាម ០១នាក់(ស្រី) អង់គ្លេស ០១នាក់ ឥណ្ឌូនេស៊ី ០១នាក់ អ៊ីតាលី ០១នាក់។ បានវាយតម្លៃបញ្ជូនឱ្យក្រុមការងារប្រកចេញ-ចូលតែមួយចំនួន ២៦០នាក់ (ស្រី ១៨នាក់)។ បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរដែលរៀបការ ទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ០៥នាក់។

### ៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តព្រះសីហនុះផ្តែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៣ករណី លើ១៣ករណី ស្មើនឹង ១០០% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៩នាក់ (ស្រី ០៣នាក់) ជនសង្ស័យជាអនីតិជន ០៣នាក់ និងជាជនជាតិវៀតណាម ០១នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ៣៥នាក់ អាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ២១នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២២នាក់ និងប្រគល់ឱ្យគ្រួសារ ១៣នាក់ ក្នុងនោះចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ០៣ករណី/០៦ករណី (ថយចុះ ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៦នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ០៥នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៥នាក់ (ប្រគល់ឱ្យគ្រួសារ ០៥នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០៤ | ០៥ |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | ០១ |
| *សរុប* | *០៣ ករណី* | *០៥ នាក់* | *០៦ នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១០ករណី/០៧ករណី (កើនឡើង ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៣នាក់ (ស្រី ០៣នាក់) ជាអនីតិជន ០៣នាក់ និងជាជនបរទេស ០១នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ៣០នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ០៩នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ១៧នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២២នាក់ និងគ្រួសារ ០៨នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | បរទេស |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០២ | ២២ | ០៥(ស្រី៣) | វៀតណាម១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ០៧ | ០៧(អនីតិជន៣) | |
| -អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ | |
| *សរុប* | *១០ ករណី* | *៣០ នាក់* | *១៣ នាក់* | *០១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ៤០០នាក់ (ស្រី ១៥៤នាក់) កុមារ ៣៩នាក់ (កុមារី ២០នាក់) សកម្មភាពមានដូចខាងក្រោម៖
  - នាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួង ស.អ.យ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សពីក្រៅប្រទេស ចំនួន ១១នាក់ (ស្រី ០៨នាក់) ប្រទេសចិន ០៦នាក់ (ស្រី) ករណីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ និងប្រទេសម៉ាឡេស៊ី ០៥នាក់ (ស្រី ០២នាក់) ករណីកេងកម្លាំងពលកម្ម។
  - មណ្ឌលសំចតប៉ោយប៉ែត បានទទួលពលករចំណាកស្រុកពីប្រទេសថៃចំនួន ៣៨៩នាក់ (ស្រី ១៤៦នាក់) កុមារ ៣៩នាក់ (កុមារី ២០នាក់)។
- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់ពីក្រៅប្រទេសចំនួន ៦១នាក់(ស្រី) ជាលទ្ធផលប្រទេសចិន ៦០នាក់ រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ២០នាក់ ស្នាក់នៅដោយខុសច្បាប់ ៤០នាក់ និងប្រទេសម៉ាឡេស៊ី ០១នាក់ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម។
  - ខេត្តស្វាយរៀង៖ ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរពីប្រទេសវៀតណាមចំនួន ០៤លើក មនុស្សចំនួន ៨៩នាក់ (ស្រី ៥៥នាក់) អនីតិជន ៧២នាក់ (ស្រី ២៤នាក់)។
  - ខេត្តព្រះវិហារ៖ ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរពីប្រទេសថៃចំនួន ០១លើក មនុស្សចំនួន ០៤នាក់ (ស្រី ០១នាក់)។
  - ខេត្តកោះកុង៖ ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរពីប្រទេសថៃចំនួន ០៤លើក មនុស្សចំនួន ០៦នាក់ (ស្រី ០២នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញ

ជួញដូរមនុស្ស ទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការការីតាសកម្ពុជា ០៣នាក់ អង្គការហាការ ០២នាក់(ស្រី) អង្គការអាដហុក ០២នាក់ អង្គការរតនៈ ០២នាក់(ស្រី) និងអង្គការ IJM ០២នាក់(ស្រី)។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅសហគមន៍វិញចំនួន ០១នាក់(ស្រី)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **អគ្គលេខាធិការដ្ឋាន** នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ បានសហការជាមួយអង្គការ IOM បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ចាម។ | ០១ | ៤០ | ៣៤ |
| **ខេត្តព្រះសីហនុ៖** មន្ទីរកិច្ចការនារីខេត្ត សហការជាក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុក/ក្រុង និងអាជ្ញាធរមូលដ្ឋានស្រុក/ក្រុង បានបើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាព ស្តីពីគោលគំនិតយេនឌ័រ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកខុសច្បាប់។ | ០៣ | ១០៨ | ៨៧ |
| **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីក្របខ័ណ្ឌថ្មី ស្តីពីវិធានការទប់ស្កាត់ការជួញដូរមនុស្ស និងកិច្ចការពារកុមារ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ | ០១ | ៩៥ | ៤៧ |
| **ខេត្តកណ្តាល៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាល ស្តីពីការស្វែងយល់ ការឆ្លើយតប និងសេវាគាំទ្របែបកុមារមេត្រី នៅដំណាក់កាលអន្តរាគមន៍វិបត្តិ សម្រាប់កុមាររងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ | ០១ | ៦០ | ២៦ |
| **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការជំនួយផ្នែកច្បាប់ស្ត្រីនិងកុមារ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពយេនឌ័រ និងការធ្វើចំណាកស្រុកទៅប្រទេសចិន តាមរយៈការរៀបអាពាហ៍ពិពាហ៍។ | ០១ | ៤០ | ២៤ |
| **ខេត្តកោះកុង៖** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីអំពើជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស និងវិធានការទប់ស្កាត់ការជួញដូរមនុស្ស និងកិច្ចការពារកុមារ " ដល់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលថ្មី។ | ០១ | ៦០ | ០៩ |
| **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការមូលនិធិអេ២១ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព អំពីការអនុវត្តនីតិវិធីនៃការធ្វើសម្ភាសន៍ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះបែបកោលសល្យវិច័យ ដល់មន្ត្រីអនុវត្តច្បាប់ និងអ្នកពាក់ព័ន្ធ ដើម្បីផ្តល់សេវាចាំបាច់នានាឱ្យបានឆ្លើយតប និងសមស្រប។ | ០១ | ៣៥ | ១៩ |

| | | | |
|---|---|---|---|
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០២ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារធាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ០៥ | ៨៣ | ៥៤ |
| **សរុប** | ១៤ លើក | ៥២១ នាក់ | ៣០០ នាក់ |

## ក.២. សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**
  - បានសហការជាមួយអង្គការ IOM រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការធ្វើបច្ចុប្បន្នភាពកិច្ចព្រមព្រៀង សហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិប្រតិបត្តិការបទដ្ឋាន (SOP) ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
  - បានសហការជាមួយអង្គការ JICA រៀបចំសិក្ខាសាលា ស្តីពីលទ្ធផលស្រាវជ្រាវលើគម្រោងបង្កើនសមត្ថភាពមន្ត្រី ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
  - បានសហការជាមួយអង្គការ IOM រៀបចំសិក្ខាសាលាបច្ចេកទេស ស្តីពីយន្តការបញ្ជូនថ្នាក់ជាតិពាក់ពន្ធ័អំពើជួញដូរមនុស្ស។
- **ក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស៖** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ (ACTIP) សមាសភាពចូលរួមពីបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា ចៅក្រម និងព្រះរាជអាជ្ញារាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រះសីហនុ ខេត្តសៀមរាប និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មការអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ក្រុមការងារក្រសួងមហាផ្ទៃទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន-កម្ពុជា (SOMTC) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម នាយកដ្ឋានការពារជនរងគ្រោះ សរុបចំនួន ៤៥នាក់ (ស្រី ១២នាក់) នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា។
- **ក្រសួងសុខាភិបាល៖** បានរៀបចំសិក្ខាសាលាបញ្ចប់សេចក្តីព្រាងផែនការសកម្មភាព ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ឆ្នាំ២០២៣-២០២៥ សមាសភាពចូលរួមមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងប្រតិភូអន្តរជាតិរួមមាន ក្រសួងសុខាភិបាលនៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រសួងសុខភាពសាធារណៈនៃព្រះរាជាណាចក្រថៃ តំណាងធនាគារអភិវឌ្ឍន៍អាស៊ី សម្របសម្រួលដោយអង្គការ IOM មានសិក្ខាកាមចូលរួមសរុប ៦៩នាក់ មកពីប្រទេសចំនួន៣ គឺ កម្ពុជា ថៃ និងឡាវ។

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  - បានសហការ ឧបត្ថម្ភគាំទ្រជាមួយអង្គការ IOM (UN MIGRATION) បានរៀបចំសិក្ខាសាលា ស្តីពីការបង្កើតនីតិវិធីបទដ្ឋាននៃយន្តការបញ្ជូនថ្នាក់ជាតិ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះ សមាសភាពចូលរួមមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងកិច្ចការនារី និងស្ថាប័ន អង្គភាពពាក់ព័ន្ធ រួមទាំងអង្គការជាតិ អន្តរជាតិ មានASIAN ACT IJM, Winrock, ERIC, A21, MAC, ACRA, ILO, UNDP, HAGAR, HOME Of JUSTIC សរុបចំនួន ៤៥នាក់ (ស្រី ១៣នាក់) នៅសណ្ឋាគារអូឡាំព្យា។
  - បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការឧបត្ថម្ភពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ និងអង្គការសម្ព័ន្ធចាប់ដៃ បានរៀបចំសិក្ខាសាលាបច្ចេកទេស ស្តីពីយន្តការបញ្ជូនបន្តថ្នាក់ជាតិពាក់ព័ន្ធអំពើជួញដូរមនុស្ស សមាសភាពចូលរួមមាន ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អគ្គស្នងការដ្ឋាននគរបាលជាតិ រដ្ឋបាលខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត (បាត់ដំបង បន្ទាយមានជ័យ និងស្វាយរៀង) មណ្ឌលទទួលពលករកំរៀង មណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត និងអង្គការសង្គមស៊ីវិលជាដៃគូ សរុបចំនួន ៦៦នាក់ (ស្រី ៣៧នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១. កិច្ចប្រជុំក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ
  - កិច្ចប្រជុំដើម្បីធ្វើប្រតិកម្មឆ្លើយតបទៅនឹងរបាយការណ៍ របស់ការិយាល័យអង្គការសហប្រជាជាតិ (OHCHR) សមាសភាពចូលរួមមាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្ស រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អគ្គនាយករងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយករងអន្តោប្រវេសន៍ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អនុប្រធាននាយកដ្ឋានកណ្តាល នៅទីស្តីការក្រសួងមហាផ្ទៃ។
  - កិច្ចប្រជុំពិភាក្សា និងកែសម្រួល លិខិតបទដ្ឋានគតិយុត្ត ដែលមានការពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់ គ.ជ.ប.ជ សមាសភាពចូលរួមមាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានមនុស្ស អនុប្រធានក្រុមប្រឹក្សានីតិកម្ម និងមន្ត្រីបច្ចេកទេស នៅទីស្តីការក្រសួងមហាផ្ទៃ។
  - កិច្ចប្រជុំបច្ចេកទេសជាមួយក្រុមការងារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិភាក្សាអំពីការរៀបចំយន្តការបញ្ជូនជនរងគ្រោះថ្នាក់ជាតិ នៅសាលប្រជុំ គ.ជ.ប.ជ។
  - កិច្ចប្រជុំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីលទ្ធផលនៃការពិនិត្យលើកំណែព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចផ្សេងៗ របស់ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
  - កិច្ចប្រជុំក្រុមគ្រូឧទ្ទេសរបស់ គ.ជ.ប.ជ ត្រៀមចុះបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំ គ.ជ.ប.ជ។

### ខ.២. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
    - ○ បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលជួបស្វាគមន៍ និងសំណេះសំណាលការងារ ជាមួយគណៈប្រតិភូវៀតណាម ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី **គៀង រីន** ស្នងការរងនគរបាលវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយសង្គ្រោះជនរងគ្រោះ តាមខេត្តជាប់ព្រំដែនទាំងពីរ នៅសាលប្រជុំ គ.ជ.ប.ជ។
    - ○ បានទទួលជួបសំណេះសំណាល ជាមួយតំណាងអង្គការអាស៊ានអាក់ ដើម្បីពិភាក្សាអំពីកិច្ចសហការរវាងគ.ជ.ប.ជ និងអង្គការអាស៊ានអាក់ ក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាលកម្ពុជា។
    - ○ បានទទួលជួបសំណេះសំណាល ជាមួយតំណាងអង្គការវីនរ៉ក់អន្តរជាតិ ដើម្បីពិភាក្សាអំពីកិច្ចសហការ រវាងគ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិ ក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាលកម្ពុជា។
- **ខេត្តត្បូងឃ្មុំ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត
    - ○ បានទទួលជួបពិភាក្សាជាមួយអង្គការ JICA ក្នុងគោលបំណងសិក្សាវាយតម្លៃ ដើម្បីសម្រេចជ្រើសរើសយកខេត្ត សម្រាប់អនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
    - ○ បានជួបប្រជុំពិភាក្សាជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣២លើក មានអ្នកចូលរួមសរុប ៨៨៣នាក់ (ស្រី ២៦៥នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១៥លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ១៦លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែតុលា ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង

ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ......................ខែ..........ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី.....៤.....ខែ...........ឆ្នាំ២០២៣
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**
-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ
**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**
-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
**"ដើម្បីជូនជ្រាប"**
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣២លើក) មនុស្សចំនួន ៨៨៣នាក់ (ស្រី ២៦៥នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.បានអញ្ជើញចូលរួម ជាអធិបតីក្នុងសន្និបាតប្រចាំឆ្នាំ នៃអង្គការសម្ព័ន្ធចាប់ដៃ លើកទី៣៧ ស្តីពីកម្លាំងនៃភាពជាដៃគូ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៧ច្បាប់ លិខិតចូល ២២ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១២ច្បាប់ លិខិតចូល ១៤ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកញ្ញា ឆ្នាំ២០២៣ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគីចំនួន៣១ច្បាប់។។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៧៦ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន៣០សកម្មភាព។ |

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - លោកប្រធានក្រុមបានចូលរួម
    - សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ អំពីលទ្ធផលសម្រេចបាននៃការអនុវត្តសកម្មភាពគម្រោង នៃការអភិវឌ្ឍន៍ផែនទីបន្ទាស់ទីប្រជាជន នៅខេត្តសៀមរាប។
    - ជាគ្រូឧទ្ទេស នៅក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ចាម។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - ឯកឧត្តម អគ្គលេខាធិការរង និងលោកប្រធានក្រុម បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការបញ្ចប់សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៣-២០២៥ របស់ថ្នាក់ជាតិ លើផ្នែកសុខភាពជនទេសន្តរប្រវេសន៍ នៅខេត្តសៀមរាប។
  - លោកប្រធាន បានចូលសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ អំពីលទ្ធផលសម្រេចបាននៃការអនុវត្តសកម្មភាពគម្រោង នៃការអភិវឌ្ឍន៍ផែនទីបន្ទាស់ទីប្រជាជន នៅខេត្តសៀមរាប។
  - ឯកឧត្តម អគ្គលេខាធិការរង លោកប្រធានក្រុម និងអនុប្រធានក្រុម បានអញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅអង្គភាពកងកម្លាំងរក្សាសន្តិភាព នៃអនុសេនាធំលេខ៤២៣ មុនចេញបំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម នៅខេត្តកំពង់ស្ពឺ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម
    - សិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ (ACTIP) នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា។
    - កិច្ចប្រជុំ ស្តីពីការស្វែងយល់អំពីទំនោរបទល្មើសជួញដូរមនុស្សថ្មីៗ ពិភាក្សាស្វែងរកធាតុចូលសម្រាប់វគ្គផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ អាស៊ានអាក់ អណត្តិថ្មី នៅសាលប្រជុំ គ.ជ.ប.ជ។
    - កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីសម្រេចព្រាង អនុស្សារណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា នៅទីស្តីការក្រសួងមហាផ្ទៃ។
  - លោកជំទាវ អគ្គលេខាធិការរង លោកប្រធានក្រុម និងលោកស្រីអនុប្រធានក្រុម បានអញ្ជើញចូលរួមធ្វើជាគ្រូឧទ្ទេស នៅក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ចាម។
  - ប្រធានក្រុម និងអនុប្រធានក្រុម បានដឹកនាំធ្វើបទបង្ហាញពីបច្ចេកទេស ក្នុងការរៀបចំទម្រង់ format ឯកសារចងក្រងជាសៀវភៅ TOT នៅលើប្រព័ន្ធហ្គូហ្គលដុក ដែលអាចចូលធ្វើការបានរួមគ្នានៅលើប្រព័ន្ធអ៊ិនធឺណិត និងបានធ្វើបច្ចុប្បន្នភាពការងារ នៅលើប្រព័ន្ធវីគី។

| | |
|---|---|
| | - លោកប្រធានក្រុមបានដឹកនាំ<br>○ កិច្ចប្រជុំ ស្តីពីការធ្វើវិភាគមុខងាររបស់ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិអន្តរជាតិ និងរៀបចំការងាររបាយការណ៍បញ្ចូលទៅតាមទីតាំងឱ្យបានត្រឹមត្រូវនៅក្នុងប្រព័ន្ធវីគី។<br>○ កិច្ចប្រជុំផ្ទៃក្នុង ខ្លឹមសារនៃកិច្ចប្រជុំ បានផ្តោតសំខាន់ទៅលើការតាមដានជំរុញ ការអនុវត្ត MOU ដោយត្រូវរៀបចំជាតារាងបច្ចុប្បន្នភាព នៅក្នុងប្រព័ន្ធវីគី និងត្រូវត្រួតពិនិត្យ និងកែសម្រួលលើការបញ្ចូលឯកសារ TOT ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាឆ្លងយោបល់ សម្រាប់ក្រុមការងារទាំង៦។<br>▪ ក្រុមជំនួយកិច្ចការអនុវត្តច្បាប់<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម<br>○ សិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ (ACTIP) នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា។<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីធ្វើប្រតិកម្មឆ្លើយតបទៅនឹងរបាយការណ៍របស់ការិយាល័យអង្គការសហប្រជាជាតិ (OHCHR)។<br>○ បានអញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅអង្គភាពកងកម្លាំងរក្សាសន្តិភាព នៃអនុសេនាធំលេខ៤២៣ មុនចេញបំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម នៅខេត្តកំពង់ស្ពឺ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៧លើក អ្នកចូលរួមសរុបចំនួន ៨៨៣នាក់ (ស្រី ២៦៥នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែកញ្ញា ត្រីមាសទី៣ រយៈពេល០៩ខែចំនួន០១លើក អ្នកចូលរួមចំនួន៥៥នាក់ ស្រី៦៦នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែសីហា ចំនួន០២លើក អ្នកចូលរួមចំនួន៧៧នាក់ ស្រី០៦នាក់។ |
| **ខេត្តតាកែវ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញាចំនួន០២លើក អ្នកចូលរួមចំនួន២៥៥នាក់ ស្រី១៥៨នាក់។ |
| **ខេត្តព្រៃវែង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញាចំនួន០១លើក អ្នកចូលរួមចំនួន២០៥នាក់។ |
| **ខេត្តសៀមរាប** | - ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែកញ្ញា ចំនួន០៨លើក អ្នកចូលរួមចំនួន២០០នាក់ ស្រី៨៦នាក់។ |
| **ខេត្តកំពត** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញាចំនួន០១លើក អ្នកចូលរួមចំនួន២៩នាក់ ស្រី១៥នាក់។ |
| **ខេត្តកំពង់ធំ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែត្រីមាសទី៣ចំនួន០១លើក អ្នកចូលរួមចំនួន៤០នាក់ ស្រី២៣នាក់។ |
| **ខេត្តស្ទឹងត្រែង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែត្រីមាសទី៣ចំនួន០១លើក អ្នកចូលរួមចំនួន២២នាក់ ស្រី១១នាក់។ |